| ឯកសារតម្រូវសម្រាប់ការស្នើសុំលិខិតអនុញ្ញាតសាងសង់សំណង់ដែលមានទំហំក្រឡាផ្ទៃ > ៣ ០០០ ម$^{២}$ | | |
|---|---|---|
| **ល.រ** | **ឯកសារតម្រូវ** | **ចំនួន (ច្បាប់)** |
| **សំណុំលិខិតស្នើសុំលិខិតអនុញ្ញាតសាងសង់ទាំងអស់របស់សាម៉ីសំណើ ត្រូវធ្វើជាភាសាខ្មែរ ដែលមានដូចតទៅ÷** | | |
| **ក. សំណុំលិខិតសុំអនុញ្ញាតសាងសង់** | | 01 |
| 1 | សំណុំលិខិតអនុញ្ញាតសាងសង់មាន ÷ | |
| | ពាក្យស្នើសុំ ត្រូវមានការចុះហត្ថលេខា ឬស្នាមមេដៃរបស់សាម៉ីសំណើ ដោយភ្ជាប់អាស័យដ្ឋាន លេខទូរស័ព្ទ និងអ៊ីម៉ែលទំនាក់ទំនង | |
| | កិច្ចសន្យាហ៊ុំព័ទ្ធការដ្ឋាន ត្រូវមានការចុះហត្ថលេខា ឬស្នាមមេដៃរបស់សាម៉ីសំណើ | |
| | រូបថតបង្ហាញទីតាំងដីឡូត៍ស្នើសុំសាងសង់ | |
| | សលាកប័ត្រដីឡូត៍ រៀបចំដោយមន្ទីរ ដនសស រាជធានី/ខេត្ត ឬដោយការិយាល័យ ដនសភ. ក្រុង ស្រុក ខណ្ឌ ឬដោយរេខាគណិតឯកជនដែលបានចុះបញ្ជីស្របច្បាប់ | |
| | ក្នុងករណីសំណង់មានផ្ទៃក្រឡាធំជាង ៥០០ម$^{២}$ (ប្រាំរយម៉ែត្រក្រឡា) ត្រូវមានបន្ថែមនូវកិច្ចសន្យារវាងម្ចាស់សំណង់ជាមួយអ្នកសិក្សាគម្រោងប្លង់ស្ថាបត្យកម្ម ដោយភ្ជាប់មកជាមួយនូវវិញ្ញាបនប័ត្រប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ | |
| | ក្នុងករណីបើសំណង់សាងសង់ជាប់ជញ្ជាំងអឡ្ឋសិទ្ធិ សំណុំលិខិតអនុញ្ញាតសាងសង់ត្រូវភ្ជាប់បន្ថែមនូវកិច្ចសន្យាសាងសង់ជាប់ជញ្ជាំងអឡ្ឋសិទ្ធិផ្សេងៗ | |
| 2 | ឯកសារកាន់កាប់ដីស្របច្បាប់ (ច្បាប់ចម្លងដែលបានធ្វើនីត្យានុកូលកម្ម) ÷ | |
| | ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ | |
| | វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬ | |
| | ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬ | |
| | កិច្ចសន្យាជួលដី មានទម្រង់ជាលិខិតយថាភូត ឬ | |
| | វិញ្ញាបនប័ត្រជួលរយៈពេលវែង ឬ | |
| | លិខិតកាន់កាប់ដីជាបណ្តោះអាសន្ន និងឯកសារកាន់កាប់ដី ដែលបានបញ្ជាក់ពីការបំពេញកាតព្វកិច្ចបង់ពន្ធប្រថាប់ត្រាតាមច្បាប់កំណត់ និងករណីអចលនវត្ថុជាប់បន្ទុកត្រូវមានលិខិតបញ្ជាក់ ឯកភាពពីម្ចាស់បំណុល | |
| 3 | អត្តសញ្ញាណសាម៉ីសំណើ ÷ | |
| 3.1 | ករណីរូបវន្តបុគ្គលៈ | |

| | | |
|---|---|---|
| | អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ច្បាប់ថតចម្លង និងស្នាមមេដៃស្តាំ) ឬ | |
| | លិខិតឆ្លងដែន (ច្បាប់ថតចម្លង និងស្នាមមេដៃស្តាំ) ឬ | |
| | សៀវភៅគ្រួសារ (ច្បាប់ថតចម្លង និងស្នាមមេដៃស្តាំ) | |
| 3.2 | ករណីនីតិបុគ្គលៈ | |
| | លក្ខន្តិកៈ និងវិញ្ញាបនប័ត្រចុះបញ្ជីក្រុមហ៊ុន ឬសមាគម ឬអង្គការ ឬលិខិតបញ្ជាក់អង្គភាពស្ថាប័នរដ្ឋ (ច្បាប់ថតចម្លង និងស្នាមមេដៃស្តាំ ឬហត្ថលេខា និងត្រា) | |
| | លិខិតប្រគល់សិទ្ធិជាតំណាងមានលក្ខណៈជាលិខិតយថាភូត | |
| | អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកទទួលសិទ្ធិ (ច្បាប់ថតចម្លង និងស្នាមមេដៃស្តាំ) | |
| **ខ. ប្លង់ស្ថាបត្យកម្មសម្រាប់ស្នើសុំលិខិតអនុញ្ញាតសាងសង់មាន** | | 10 |
| 1 | ប្លង់បង្ហាញទីតាំង (ត្រូវបង្ហាញទិសខាងជើងទៅលើមាត្រដ្ឋាន ១/៥០០ ទៅ ១/១០០០០) | |
| 2 | ប្លង់សរុប (ដោយបង្ហាញទិសខាងជើងទៅលើ) មាត្រដ្ឋាន ១/២០០ ទៅ ១/១០០០ | |
| 3 | តារាងឈ្មោះអគារ ឈ្មោះសន្លឹកប្លង់ ក្រឡាផ្ទៃសំណង់គ្រប់បន្ទប់គ្រប់ជាន់ ក្រឡាផ្ទៃសរុបផលធៀប ផ្ទៃបាតសំណង់ និងសន្ទស្សន៍ប្រើប្រាស់ដី ច្រកសង្គ្រោះបន្ទាន់ និងទីតាំងបំពាក់ឧបករណ៍ ពន្លត់អគ្គីភ័យ មាត្រដ្ឋាន ១/១០០ | |
| 4 | ប្លង់ដំបូលមាត្រដ្ឋាន ១/១០០ | |
| 5 | ប្លង់មុខភាពនៃអគារគ្រប់ទិស មាត្រដ្ឋាន ១/១០០ | |
| 6 | ប្លង់ពុះយ៉ាងតិចចំនួនពីរ (បង្ហាញដូចប្លង់មុខភាព) មាត្រដ្ឋាន ១/១០០ | |
| 7 | ប្លង់បណ្ដាញក្រោមដី : ប្រព័ន្ធបណ្ដាញលូ អាងប្រព្រឹត្តកម្មទឹកកខ្វក់ និងអាងបង្គន់អនាម័យ... | |
| 8 | ប្លង់ត្រូវគូរលើក្រដាស់ A3, A2, A1, ឬA0 លើកលែងតែក្នុងករណីចាំបាច់ដែលប្លង់មានទំហំធំ អាចប្រើមាត្រដ្ឋាន ១/២០០ | |
| 9 | គ្រប់សន្លឹកប្លង់ត្រូវធ្វើតាមគំរូផ្លូវការរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | |
| **គ. ក្នុងករណីចាំបាច់លិខិតអនុញ្ញាតសាងសង់ ត្រូវមានមតិយោបល់បន្ថែមពីសមត្ថកិច្ចជំនាញពាក់ព័ន្ធ÷** | | 01 |
| 1 | ស្ថានីយ៍ប្រេងឥន្ធនៈ ÷ | |
| | លិខិតបញ្ជាក់មាត្រដ្ឋានបច្ចេកទេស បង្ការអគ្គីភ័យរបស់អង្គភាពនគរបាលបង្ការ និង ពន្លត់អគ្គីភ័យ របស់រាជធានី ខេត្តសមី | |
| | លិខិតបញ្ជាក់ពីការឯកភាព របស់ម្ចាស់អចលនទ្រព្យដែលមានទីតាំងជាប់នឹងព្រំដីស្នើសុំសាងសង់ | |

| | | |
|---|---|---|
| | លិខិតបញ្ជាក់ពីការបិទផ្សាយជាសាធារណៈរយៈពេល ២៥ថ្ងៃរបស់ការិយាល័យ ដនសភក្រុង ស្រុក ខណ្ឌ | |
| | លិខិតបញ្ជាក់ពីក្រសួង ឬមន្ទីររ៉ែ និងថាមពល | |
| 2 | ឃ្លាំង ÷ | |
| | លិខិតបញ្ជាក់រយៈកម្ពស់ពីរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ចំពោះសំណង់ដែលស្ថិតក្នុងដែនហោះហើរជិតតំបន់អាកាសយានដ្ឋាន | |
| | លិខិតបញ្ជាក់របស់ម្ចាស់សំណើអំពីប្រភេទទំនិញដែលស្តុក (មានលក្ខណៈជាយថាភូត) | |
| 3 | រោងចក្រ ÷ | |
| | លិខិតបញ្ជាក់រយៈកម្ពស់ពីរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ចំពោះសំណង់ដែលស្ថិតក្នុងដែនហោះហើរ ជិតតំបន់អាកាសយានដ្ឋាន | |
| | លិខិតបញ្ជាក់របស់ម្ចាស់សំណើអំពីប្រភេទរោងចក្រ (មានលក្ខណៈជាយថាភូត) | |
| | លិខិតយល់ព្រមពីក្រសួងសាធារណៈការ (បើជាប់ផ្លូវជាតិ) | |
| 4 | អគារស្នាក់នៅរួម ÷ | |
| | លិខិតបញ្ជាក់មាត្រដ្ឋានបច្ចេកទេស បង្ការអគ្គិភ័យរបស់អង្គភាពនគរបាលបង្ការ និងពន្លត់អគ្គិភ័យ របស់រាជធានី ខេត្តសាមី (ករណីអគារកម្ពស់មធ្យម និងខ្ពស់) | |
| | លិខិតបញ្ជាក់រយៈកម្ពស់ពីរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ចំពោះសំណង់ដែលស្ថិតក្នុងដែនហោះហើរជិតតំបន់អាកាសយានដ្ឋាន | |